**សកម្មភាព** ៖ **ល្បែងសង់អគារ**

**ចិត្តចលភាព**

បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)។

**វិទ្យាសាស្រ្ត**

អំពីរាងកាយផ្ទាល់ខ្លួន (ការប្រើប្រាស់សម្ភារៈតាមបច្ចេកវិទ្យា)

**បុរេគណិត**

រង្វាស់រង្វាល់ (បញ្ញត្តិស្តីពីរង្វាស់រង្វាល់)

**គោលបំណង** ៖

**(ចិត្តចលភាព)** ប្រាប់ពីររបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬលេងល្បែង។

បង្ហាញពីរបៀបធ្វើសកម្មភាពទៅតាមទម្រង់ផ្សេងៗនៃសកម្មភាពរួមមួយ។

**(វិទ្យាសាស្រ្ត)** សាងសង់សំណង់សាមញ្ញៗដោយប្រើក្រដាស ដីឥដ្ឋ ឬដុំឈើ ឬដុំឥដ្ឋដូចជាធ្វើទូក កូនឡាន ជាដើម។

**(បុរេគណិត)** ប្រាប់ពីបញ្ញត្តិ (ខ្ពស់ និងទាប  ធំ និងតូច វែង និងខ្លី)។

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង "តើអ្នកពូកែអី?"។

[សៀវភៅ តើអ្នកពូកែអី?]

**កម្រិត** ៖ មធ្យម ទាប ខ្ពស់

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ សម្ភារសាងសង់ អាស្រ័យលើវត្ថុដែលអ្នកមានក្នុងថ្នាក់រៀនស្រាប់។

(ឧទាហរណ៍៖ គម្របដប កែងជ័រ កំណាត់ឈើជាដើម)

សម្ភារទាំងនេះអាចជាសម្ភារដដែលសម្រាប់ក្រុមនីមួយៗ ដូចនេះក្រុមទាំងអស់ នឹងប្រកួតប្រជែងដោយស្មើភាពគ្នា ដើម្បីសង់អគារខ្ពស់ជាងគេ ឬសម្ភារទាំនោះអាចជាសម្ភារខុសគ្នា ដែលនាំទៅរកការពិភាក្សានៅពេលក្រោយអំពី ថាតើហេតុអ្វីសម្ភារមួយ ធ្វើការល្អជាងសម្ភារមួយទៀត។

**ការរៀបចំ** ៖ ប្រមូលសម្ភារសាងសង់ ហើយដាក់វានៅកន្លែងដែលអ្នកចង់ឱ្យក្មេងៗសាងសង់គារ។ ដាក់កៅអីនៅក្បែរ ដើម្បីឱ្យពួកគេអាចឡើងបាន ប្រសិនបើអគាររបស់ពួកគេខ្ពស់ពេកសម្រាប់ពួកគេឡើង

សង់អាគាររបស់ពួកគេ។ បែងចែកកុមារ ជាក្រុមតូចៗ។

**ការណែនាំ៖**

1. និយាយ៖ ថ្ងៃនេះអ្នកគ្រូនឹងលេងល្បែង**ល្បែងសង់អគារ** ជាមួយកូនៗទាំងអស់គ្នា។
2. សួរក្មេងៗថា៖ តើមានកូនៗណាចាំរឿង "តើអ្នកពូកែអី? "ដែរឬទេ?។

(បើក្មេងៗមិនចងចាំ ឬមិនធ្លាប់ស្តាប់លោកអ្នកអាចរំលឹក ឬអានរឿងហ្នឹងម្តងទៀតបាន)។

3. ចូរសរសេរពាក្យថា “ខ្ពស់” នៅលើក្តារខៀន។
   តើកូនៗដឹងថាយ៉េកពូកកែខាងអ្វី? បាទ/ចាស ឈោងដៃយករបស់នៅកន្លែងខ្ពស់។
   តើកូនៗដឹងទេថានៅក្នុងសៀវភៅមាននរណាទៀតដែលខ្ពស់ជាងយ៉េង?
   បាទ/ចាស គ្មាននរណាខ្ពស់ជាងយ៉េកទេ។
4. សរសេរពាក្យថា “ខ្ពស់ជាងគេ” នៅលើក្តារខៀន។
5. ចូរសរសេរពាក្យថា “ទាប” នៅលើក្តារខៀន។
   តើកូនៗដឹងថាមករាពូកកែខាងអ្វី? បាទ/ចាស ពូកែរៀនភាសាខ្មែរ ប្រកបពាក្យ។
   តើកូនៗដឹងទេថានៅក្នុងសៀវភៅមាននរណាទៀតដែលទាបជាងមករា?
   បាទ/ចាស គ្មាននរណាទាបជាងមករាទេ។
6. សរសេរពាក្យថា “ទាបជាងគេ” នៅលើក្តារខៀន។
7. កូនៗត្រូវមើលពាក្យដែលអ្នកសរសេរលើក្តារខៀនហើយព្យាយាមចងចាំពាក្យទាំងនោះ។
8. ប្រាប់ក្មេងៗ៖ អគាររបស់យើងត្រូវរឹងមាំ ហើយមិនងាយរលំ កូនៗអាចមានគំនិតច្នៃប្រឌិតតាមដែលចង់បាន ប៉ុន្តែគោលដៅរបស់កូនៗគឺត្រូវសង់អគារឱ្យបានខ្ពស់។
9. កូនៗត្រូវចែកជាក្រុមនឹងត្រូវសហការគ្នាក្នុងការសាងសង់។ ដូចម្តេចដែលហៅថាសមាជិកក្រុមដ៏ល្អ? ឧទាហរណ៍៖ ខណៈពេលដែលពួកគេកំពុងសង់អគារ កូនៗអាចជួយសមាជិកក្រុម ដោយដាក់សម្ភារមួយៗទៅលើអគារតែគួរដាក់វាថ្នមៗ ទើបអគារមិនរលំ។ ប៉ុន្តែកូនមិនគួរខឹងនឹងខ្លួនឯង ឬ សមាជិកក្រុមដទៃទៀតឡើយ ប្រសិនបើអគារដួលរលំ។
10. ចូររលឹកដល់ពួកគេ ប្រសិនបើពួកគេមានពេលសល់ត្រឹមតែ ២នាទីទៀតប៉ុណ្ណោះ ក្នុងការសាងសង់អគារ។
11. នៅពេលអស់ម៉ោងចូរឱ្យក្រុមនីមួយៗ ម្តងមួយក្រុម ដើរពិនិត្យមើលអគាររបស់ក្រុមដទៃ។

12. កូនៗគួររក្សាគម្លាតពីអគារ ដើម្បីចៀសវាការប៉ះរលំអគារទាំងនោះ និងធ្វើឱ្យអាគារអ្នកដទៃរលំ។

13. ចូរពិភាក្សាអំពីអគារដែលពួកគេបានសាងសង់។

តើអគារមួយណាខ្ពស់ជាងគេ? អគាររបស់ក្រុម··· ខ្ពស់ជាងគេ។

តើអគារមួយណាទាបជាងគេ? អគាររបស់ក្រុម...ទាបជាងគេ។

ហេតុអ្វីបានជាអគារ១ខ្ពស់ជាងអគារមួយទៀត? បាទ/ចាស រៀបតាមលំដាប់លំដោយ។

(តម្រៀបតាមលំដាប់លំដោយ ពីធំទៅតូច តាមប្រភេទ)

តើសម្ភារសាងសង់ធ្វើឱ្យកម្ពស់មានភាពខុសគ្នាដែរឬទេ? បាទ/ចាស មានភាពខុសគ្នា។

អ្នកអាចសួរសំណួរផ្សេងទៀត ដែលអ្នកគិតថាគួរឱ្យចាប់អារម្មណ៍ ឬ មានប្រយោជន៍។

**បម្រែបម្រួល៖** អ្នកគ្រូអាចជ្រើសរើសសម្ភារសាងសង់តាមចិត្ត។